ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៩១
ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០២១
**ជំនុំជម្រះលេខ ៥៧៤**
ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២១
**សាលក្រមព្រហ្មទណ្ឌ**
លេខ ១០ ខ/៥៨
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការសួរដេញដោលក្នុងសវនាការជាសាធារណៈនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៩ និង០០ នាទីព្រឹក ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាអនុប្រធានសាលាដំបូងខេត្តសៀមរាប

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៩១ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

គោត្តនាម និងនាម [redacted] **ក្អាត់** ភេទប្រុស អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ធិ (ស) ម្តាយឈ្មោះ [redacted] ភួយ (ស) ប្រពន្ធឈ្មោះ [redacted] យ៉ុន (ស) មានកូន ៥នាក់ ប្រវត្តិនៃការផ្តន្ទាទោស៖ គ្មាន ។

ដីកាសម្រេចមិនឃុំខ្លួនលេខ ៧៤៨ ដពស/ឈ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១។

ជាប់ចោទពីបទ៖ កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ប្រព្រឹត្តនៅចំណុច ឬនិយាមកាត្រពាំងផ្អោលធំ ស្ថិតនៅភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៩៨ ចំណុច១ នៃច្បាប់ស្តីពីជលផល។

-ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ក្អាត់។

**<u>អង្គហេតុដែលចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះ</u>**

យោងតាមអង្គហេតុដែលមានក្នុងដីកាដំណោះស្រាយបញ្ជូនរឿងមកជំនុំជម្រះ៖ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ នៅចំណុចឬនិយាមកា ត្រពាំងផ្អោលធំ និងត្រពាំងថ្ម ស្ថិតក្នុងភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ផ្នែករដ្ឋបាលជលផលចុងឃ្នៀស សហការណ៍ជាមួយរដ្ឋបាលក្រុងសៀមរាប រដ្ឋបាលសង្កាត់ស្រង៉ែ ដឹកនាំដោយលោក [redacted] យង់ ប្រធានការិយាល័យសាធារណការ និងអភិវឌ្ឍន៍ក្រុង បានចុះពិនិត្យការ កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ធ្វើស្រែប្រាំង នៅតំបន់៣

ដែលកាប់គាស់ ក្នុងអំឡុងឆ្នាំ២០១៨ ហើយក្រុមការងារបានធ្វើកិច្ចសន្យាបញ្ឈប់ឈ្មោះ [redacted] ក្អាត់ ដែលបានកាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ធ្វើស្រែប្រាំងរួចម្តងមកហើយ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២០។ តែរហូតមកដល់បច្ចុប្បន្ននេះឈ្មោះ [redacted] ក្អាត់ នៅតែបន្តក្តួរាស់យកដីធ្វើស្រែបន្តទៀតអស់ចំនួន ១០.៧៨ ហិតា។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៦៣ អយគ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៣៥០០ ៣ស.ព្រស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៩៩០ ៣ស.ព្រជ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## **នាពេលសវនាការ**

-ក្រោយពីបានស្តាប់ចម្លើយរបស់៖

-ជនជាប់ចោទឈ្មោះ [redacted] ក្អាត់ ភេទប្រុស

-អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌លោក [redacted] សិទ្ធិ ជារងខណ្ឌរដ្ឋបាលជលផល

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ។

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។

## **សំអាងហេតុ**

១-ជនជាប់ចោទឈ្មោះ [redacted] ក្អាត់ ជាប់ចោទពីបទ កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ប្រព្រឹត្តនៅចំណុច ឬនិយាមកាត្រពាំងផ្គោលធំ ស្ថិតនៅភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៣៥០០ ៣ស.ព្រស ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប។

២-តាមលទ្ធផលនៃការពិភាក្សាដេញដោល និងពិនិត្យភស្តុតាងក្នុងពេលសវនាការ ឃើញថា កាលពីអំឡុងឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ នៅចំណុច ឬនិយាមកាត្រពាំងផ្គោលធំ ស្ថិតនៅភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ពិតជាមានអង្គហេតុ កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ប្រព្រឹត្តដោយឈ្មោះ [redacted] ក្អាត់ ប្រាកដមែន។

៣-ភស្តុតាងដាក់បន្ទុករួមមាន ៖

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ក្អាត់ ភេទប្រុស បានសារភាពថា៖ កាលពីអំឡុងឆ្នាំ១៩៩៧ ខ្លួនបានចូលទៅធ្វើស្រែនៅលើដីមួយកន្លែងទំហំ ១០ហិកតា នៅចំណុចត្រពាំងផ្គោលធំ និងនៅចំណុចត្រពាំងថ្ម ស្ថិតនៅភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ពុំដែលមានបញ្ហាអ្វីទេ។ រហូតដល់ឆ្នាំ២០២០ ស្រាប់តែអាជ្ញាធរបានចុះមកហាមឃាត់រូបខ្លួន មិនឱ្យចូលទៅធ្វើស្រែនៅទីតាំងដីខាងលើទៀតនោះទេ។ បន្ទាប់ពីមានការហាមឃាត់ពីអាជ្ញាធរ រូបខ្លួនពុំបានចូលទៅធ្វើស្រែនៅលើទីតាំងខាងលើទៀតនោះទេ គឺខ្លួនសុខចិត្តប្រគល់ដីជូនរដ្ឋ។

-តាមអំណានចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌លោក [redacted] សិទ្ធិ ជានាយរងខណ្ឌរដ្ឋបាលជលផល បានបំភ្លឺថា៖ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ ផ្នែករដ្ឋបាលចុងឃៀស សង្កាត់រដ្ឋបាលជលផលផ្សារលើបានសហការណ៍ជាមួយរដ្ឋបាលក្រុងសៀមរាប រដ្ឋបាលសង្កាត់ស្រង៉ែ ដឹកនាំដោយលោក ហាយ យង់ ប្រធានការិយាល័យសាធារណៈការ និងអភិវឌ្ឍន៍ក្រុង បានចុះត្រួតពិនិត្យការ កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក នៅក្នុងតំបន់៣ (ជាតំបន់ហាមឃាត់) ដែលប្រព្រឹត្តឡើងដោយឈ្មោះ [redacted] ក្លាត់។ នៅអំឡុងឆ្នាំ២០១៨ ក្រុមការងារធ្លាប់បានចុះត្រួតពិនិត្យមើល ហើយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ក្រុមការងារបានធ្វើកិច្ចសន្យាបញ្ឈប់ជនត្រូវចោទឈ្មោះ [redacted] ក្លាត់ មិនឱ្យចូលទៅកាន់កាប់ទន្រ្ទានព្រៃលិចទឹកខាងលើទៀតនោះទេ។ ប៉ុន្តែឈ្មោះ [redacted] ក្លាត់ នៅតែបន្តភ្ជួររាស់យកដីព្រៃលិចទឹកធ្វើស្រែបន្ត។ ក្រោយមកអង្គភាពខណ្ឌរដ្ឋបាលជលផលសៀមរាប កសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

៤-តាមចម្លើយសារភាពរបស់ជនជាប់ចោទ មន្ត្រីនគរបាលយុត្តិធម៌ ពិនិត្យកស្តុតាង មានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់បានថា៖ កាលពីអំឡុងឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ ពិតជាមានករណី កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ដែលប្រព្រឹត្តដោយជនជាប់ចោទ ប្រាកដមែន។

៥-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ មានធាតុផ្សំគ្រប់គ្រាន់នៃបទល្មើស កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៩៨ ចំណុច១ នៃច្បាប់ស្តីពីជលផល ដូចការចោទប្រកាន់របស់តំណាងអយ្យការ។

៦-មានកស្តុតាងគ្រប់គ្រាន់កំណត់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ក្លាត់ ពីបទ៖ កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក ប្រព្រឹត្តនៅចំណុច ឬនិយាមកាត្រពាំងផ្លោលធំ ស្ថិតនៅភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៩៨ ចំណុច១ នៃច្បាប់ស្តីពីជលផល។

៧-ការប្រកាសទោស៖ គប្បីប្រកាសទោសចំពោះជនជាប់ចោទក្នុងកម្រិតអប្បបរមានៃទោស និងឲ្យមានការព្យួរនូវការអនុវត្តទោសជម្មតាទាំងមូលស្របតាមមាត្រា១០៤ ដល់មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

៨-នាពេលប្រព្រឹត្តបទល្មើសជនជាប់ចោទ គឺជានីតិជនដែលមានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួន។

៩-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានថា រក្សាការចោទប្រកាន់លើជនជាប់ចោទតាមដីកាសន្និដ្ឋានស្ថាពរ និងប្តឹងសុំទៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។ គប្បីតុលាការពិចារណា។

## **វិនិច្ឆ័យសេចក្តី**

**១.ផ្តន្ទាទោស** ឈ្មោះ [redacted] **ក្លាត់** ភេទប្រុស អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]

[redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] (ស) ម្តាយ ឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (ស) មានកូន ៥នាក់ ប្រវត្តិនៃការផ្តន្ទាទោសៈ គ្មាន ។

**ដាក់ពន្ធនាគារកំណត់ ០៣ (បី) ឆ្នាំ** តែទោសនេះ ត្រូវព្យួរការអនុវត្តជម្មតាទាំងមូល ស្របតាមមាត្រា១០៤ ដល់មាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទៈ **កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុច ឬនិយាមកាត្រពាំងផ្អៅលធំ ស្ថិតនៅភូមិចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងឆ្នាំ២០១៨ និងថ្ងៃទី៣០ ខែមករា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៩៨ **ចំណុច១** នៃច្បាប់ស្តីពីជលផល។

សាលក្រមនេះបញ្ចប់ការជំនុំជម្រះនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា

[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ពស.២៥៦៥
សៀមរាប, ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner